https://www.vodkhmer.news/2020/05/07/more-200-workers-hulu-factory-submitted-their-case-arbitration-council/ Go
10 captures
20 Jun 2020 - 30 Sep 2023
JUN FEB SEP
13
2020 2023 2024
About this capture



# កម្មករជាង២០០នាក់នៅរោងចក្រ ហ៊ូលូ ស្នើបញ្ជូនសំណុំរឿងពួកគេទៅដោះស្រាយបន្តនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ព័ត៌មានជាតិ | ការងារ | តុលាការ និងច្បាប់ - លោក យុត សុគន្ធ | ០៧ ឧសភា ២០២០ ម៉ោង ១៦:៤១



កម្មកររោងចក្រ ហ៊ូលូ (HULU Garment Co. Ltd.) នៅភូមិព្រៃទា ១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាំគ្នាតវ៉ាមុខរោងចក្រ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ទាមទារក្រុមហ៊ុនឱ្យផ្ដល់ប្រាក់ដំណាច់ឆ្នាំ។ (កម្មករ)

កម្មករជាង ២០០នាក់ បម្រើការងារនៅរោងចក្រ ហ៊ូលូ (HULU Garment Factory) ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្នើបញ្ជូនសំណុំរឿងរបស់ពួកគេទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយបន្តក្រោយពីការដោះស្រាយនៅក្រសួងការងារមិនឈានទៅដល់ចំណុចឯកភាពគ្នា។

កាលពីថ្ងៃទី២៨ ខែមេសាកន្លងមកនេះ កម្មករ ២២៤នាក់ បម្រើការងារនៅរោងចក្រ ហ៊ូលូ បាននាំគ្នាផ្ដិតមេដៃប្ដឹងទៅក្រសួងការងារឱ្យជួយដោះស្រាយវិវាទរបស់ពួកគេ ដោយចោទថា ថៅកែរោងចក្រមួយនេះ បញ្ឈប់ពួកគេពីការងារទាំងមិនបានផ្ដល់សំណងតាមផ្លូវច្បាប់។

កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី៧ ខែឧសភា ដែលវីអូឌីទទួលបាន បង្ហាញថា ការសម្របសម្រួលពីមន្ត្រីក្រសួងការងារជាមួយតំណាងកម្មករ និងតំណាងក្រុមហ៊ុននៅថ្ងៃនេះ មិនបានឈានទៅរកដំណោះស្រាយឡើយ ហើយកម្មករស្នើបញ្ជូនសំណុំរឿងនេះទៅដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តទៀត។

កំណត់ហេតុបានបញ្ជាក់ថា ចំណុចដែលមិនឯកភាពគ្នានោះ គឺកម្មករទាមទារទៅថៅកែឱ្យទូទាត់ប្រាក់ជូនដំណឹងមុនប្រាក់បណ្ដេញចេញពីការងារ និងប្រាក់សំណងជំងឺចិត្ត ប៉ុន្តែ ភាគីថៅកែបដិសេធផ្ដល់សំណងតាមការទាមទារនេះទេ។

ប្រធានសហព័ន្ធសហជីពឯករាជ្យ លោក រី សិទ្ធីណែត ដែលចូលរួមដោះស្រាយជាមួយកម្មករនៅទីស្ដីការក្រសួងនៅថ្ងៃនេះ ប្រាប់ថា ករណីថៅកែបញ្ឈប់កម្មករពីការងារនោះ គឺមិនបានជូនដំណឹងត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ។

មេដឹកនាំសហជីពរូបនេះ បន្តទៀតថា ភាពខ្វែងគំនិតគ្នាមួយទៀតនោះ គឺកម្មករអះអាងថា ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ថៅកែមិនទាន់បានទូទាត់ប្រាក់អតីតភាពការងារជូនពួកគេទេ។

> “ លោកបន្ថែមថា៖ «**ទាក់ទងករណីនេះ យើងទាមទារឱ្យបញ្ជូនសំណុំរឿងទៅដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្ត ដោយសារតែការជូនដំណឹងរបស់ថៅកែហ្នឹង គឺអត់ធ្វើទៅតាមនីតិវិធីច្បាប់។ ហើយអ្វីដែលយើងជជែកខ្វែងគំនិតគ្នាទៀតនោះ គឺនៅចន្លោះពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ខាងភាគីរោងចក្រគាត់ថា បានសងលុយទៅកម្មកររួចហើយ ប៉ុន្តែ ខាងកម្មករថា ខាងរោងចក្រមិនទាន់បានសងទៅកម្មករទេ។ អ៊ីចឹង ដោយសារតែនិយាយមិនត្រូវគ្នា យើងស្នើបន្តនីតិវិធីបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលទៅ**»។

កម្មការិនីម្នាក់ អ្នកស្រី យី សុគន្ធា ដែលអះអាងថា បម្រើការងារនៅរោងចក្រ ហ៊ូលូ អស់រយៈពេល ១៥ឆ្នាំមកហើយនោះ និយាយថា ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ គឺអ្នកស្រីមិនទាន់ទទួលបានការទូទាត់ប្រាក់អតីតភាពការងារនៅឡើយទេ។ អ្នកស្រីសង្ឃឹមថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងផ្ដល់យុត្តិធម៌សម្រាប់អ្នកស្រី និងកម្មករផ្សេងទៀតដែលកំពុងរង់ចាំដំដោះស្រាយ។

> “ អ្នកស្រីបន្ថែមថា៖ «**យើងជួបបញ្ហាច្រើនដោយសារបញ្ហាជំងឺកូវីដ អ៊ីចឹង យើងពិបាករកការងារកន្លែងថ្មីធ្វើ ការចាយវាយ។ បើយើងនៅធ្វើការងារ យើងផ្គត់ផ្គង់ជីវភាពគ្រប់គ្រាន់ ដល់ពេលយើងបាត់បង់ការងារ ការចាយវាយក៏មានការខ្វះខាតដែរ។ ខ្ញុំសូមសំណូមពរទៅខាងអាជ្ញាកណ្ដាលជួយដោះស្រាយដល់ពួកខ្ញុំជាកម្មករដែលខាងរោងចក្របញ្ឈប់ពួកខ្ញុំដោយមិនបានគោរពតាមច្បាប់ការងារ**»។

ប្រធានរដ្ឋបាលរោងចក្រ ហ៊ូលូ លោក ជ័យ សុវ័ត្ន ប្រាប់ថា រោងចក្រ ហ៊ូលូ មិនបានបិទទ្វារនោះទេ។ លោកថា ករណីរោងចក្របញ្ឈប់កម្មករ និងព្យួរការងារកម្មករកន្លងមកនេះ ដោយសារខ្វះវត្ថុធាតុដើមសម្រាប់ដំណើរការផលិត និងគ្មានអ្នកបញ្ជាទិញ។

ប្រធានរដ្ឋបាលរោងចក្ររូបនេះបន្តថា ករណីកម្មករបន្តប្ដឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះ វាជាសិទ្ធិរបស់កម្មករ ដោយថា កម្មករដែលត្រូវបានបញ្ឈប់នោះ គឺក្រុមហ៊ុនបានដោះស្រាយតាមច្បាប់រួចរាល់ហើយ ដោយទទួលបានប្រាក់ខែចុងក្រោយ ប្រាក់ជូនដំណឹង ១៥ថ្ងៃ ប្រាក់ដំណាច់ឆ្នាំ និងប្រាក់ដំណាច់អតីតភាពការងារ។

> “ លោកបន្ថែមថា៖ «**អាហ្នឹងជាសិទ្ធិរបស់ពួកគាត់ ព្រោះខាងដោះស្រាយវិវាទ គាត់បានផ្សះផ្សាដែរ ប៉ុន្តែ គាត់ថា មិនត្រូវ ហើយខាងក្រសួងគេបានពន្យល់ហើយពាក់ព័ន្ធបញ្ហាហ្នឹង។ ប៉ុន្តែ គាត់នៅតែទាមទារចំណុចផ្សេងទៀត ខ្ញុំមិនយល់ដែរ**»។

វីអូឌីមិនអាចសុំការបញ្ជាក់ពីតំណាងក្រសួងការងារបានទេ ថាតើសំណុំរឿងនេះនឹងបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលពេលណាបាននោះ។

បើតាមអ្នកស្រី យី សុគន្ធា រោងចក្រ ហ៊ូលូ (HULU Garment Factory) មានកម្មករជាង ១ពាន់នាក់ ប៉ុន្តែ ត្រូវបានថៅកែព្យួរ និងបញ្ឈប់ពីការងារអស់ជាង ៥០០នាក់ហើយ ក្រោមហេតុផលគ្មានអ្នកបញ្ជាទិញ និងខ្វះវត្ថុធាតុដើម។

កាលពីខែមេសាកន្លងមក កម្មករជាង ២០០នាក់ នៅរោងចក្រ ហ៊ូលូ បានផ្ទុះការតវ៉ាជាបន្តបន្ទាប់ ដោយចោទថា ថៅកែរោងចក្រនេះបានក្លែងបន្លំលិខិតបញ្ឈប់ពួកគេពីការងារខុសនីតិវិធី និងមិនបានដោះស្រាយសំណងតាមច្បាប់ជូន

ព័ត៌មានថ្មីៗ | បោះឆ្នោត



ពួកគេ។

ប្រធានសហព័ន្ធសហជីពឯករាជ្យ លោក រី សិទ្ធីណែត ឱ្យដឹងថា តាមលោកគណនាបឋម គឺថៅកែរោងចក្រ ហ៊ូលូ នៅជំពាក់សំណងកម្មករក្នុងម្នាក់ប្រហែល ៣ពាន់ដុល្លារ៕


**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។


## អត្ថបទទាក់ទង

### សូមផ្តល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចេញមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន


VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យក្នុងស្រុកមួយ ដែលផ្តល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។

info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ



GET IT ON Google Play

Download on the App Store








© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម